ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

**អគ្គនាយកដ្ឋានអាស៊ាន**

**សេចក្តីប្រកាសព័ត៌មាន**

«សម្រាប់ការផ្សព្វផ្សាយភ្លាម»

# «លទ្ធផលនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន លើកទី២៧ កិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន លើកទី៣៤»

រាជធានីភ្នំពេញ ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣ - តបតាមការអញ្ជើញរបស់**លោកជំទាវ រ៉េតណូ ម៉ាស៊ូឌី** រដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋឥណ្ឌូនេស៊ី **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ ចិន្តាសោភា** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន (AMM) កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន (APSC) លើកទី២៧ និងកិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន (ACC) លើកទី៣៤ នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ នៅទីក្រុងហ្សាការតា សាធារណរដ្ឋឥណ្ឌូនេស៊ី។

## ១. កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន (AMM)

កិច្ចប្រជុំ AMM បានផ្តោតលើដំណើរការនៃការកសាងសហគមន៍អាស៊ាន ក្រោមការដឹកនាំរបស់ឥណ្ឌូនេស៊ី ដែលជាប្រធានអាស៊ានឆ្នាំ២០២៣ ក្រោមមូលបទ៖ **"សារៈសំខាន់អាស៊ាន៖ ស្នូលនៃកំណើន"** វិធីសាស្ត្រដើម្បីពន្លឿនវឌ្ឍនភាពនៃការអនុវត្តកិច្ចព្រមព្រៀងជាឯកច្ឆន្ទ៥ចំណុច (5PC) និងទំនាក់ទំនងអាស៊ានជាមួយដៃគូសន្ទនា និងដៃគូផ្សេងៗទៀត។

រដ្ឋមន្ត្រីការបរទេសអាស៊ានបានបង្ហាញនូវការពេញចិត្ត ចំពោះសន្ទុះជាវិជ្ជមាននៃដំណើរការកសាងសហគមន៍អាស៊ាន និងការកើនឡើងនៃចំនួនប្រទេសខាងក្រៅតំបន់ ដែលបានបង្ហាញនូវបំណងចូលជាភាគីនៃសន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC)។ នេះជាការឆ្លុះបញ្ចាំងអំពីការទទួលស្គាល់នូវសារៈសំខាន់នៃមជ្ឈភាពអាស៊ាន ក្នុងការរក្សា និងលើកកម្ពស់សន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាព ក្នុងតំបន់ និងក្រៅតំបន់។

រដ្ឋមន្ត្រីការបរទេសអាស៊ានបានលើកទឹកចិត្តឱ្យមានវឌ្ឍនភាពបន្ថែមទៀត ក្នុងការអនុវត្ត 5PC និងបានគូសបញ្ជាក់ថា 5PC រួមទាំងការពិនិត្យឡើងវិញ និងការសម្រេចចិត្តរបស់ប្រមុខដឹកនាំ

អាស៊ានស្តីពីការអនុវត្ត 5PC គឺនៅតែជាឯកសារស្នូល ដើម្បីជួយមីយ៉ាន់ម៉ាឱ្យវិលត្រឡប់ទៅរកប្រក្រតីភាពឡើងវិញ។ កិច្ចប្រជុំបានសង្កត់ធ្ងន់បន្ថែមថា 5PC បានដើរតួនាទីជាឧបករណ៍ចាំបាច់ក្នុងការបង្កើតបរិយាកាសអំណោយផលឆ្ពោះទៅការបង្កើតកិច្ចសន្ទនាប្រកបដោយសន្តិវិធី ក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ នៅមីយ៉ាន់ម៉ា ដើម្បីជាប្រយោជន៍ដល់ប្រជាជនមីយ៉ាន់ម៉ា។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ឡើងវិញនូវការគាំទ្ររបស់កម្ពុជាចំពោះឥណ្ឌូនេស៊ី ដែលបានខិតខំជំរុញឱ្យមានកិច្ចសន្ទនារវាងភាគីពាក់ព័ន្ធ ហើយ **ឯកឧត្តម** ក៏បានរំលឹកឡើងវិញនូវភាពចាំបាច់ក្នុងការរក្សាសាមគ្គីភាពអាស៊ាន ក៏ដូចជាការតស៊ូដោះស្រាយវិញ្ញាសាស្តីពីមីយ៉ាន់ម៉ាដែលមានលក្ខណៈ ស្មុគស្មាញខ្លាំង។

នៅក្នុងកិច្ចប្រជុំនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានគូសបញ្ជាក់ថា អាស៊ានបានបង្ហាញច្បាស់ពីស្មារតីឯកភាពគ្នាជាធ្លុងមួយក្នុងការពុះពារឆ្លងកាត់បញ្ហាប្រឈមពហុសណ្ឋានជាច្រើន និងបានក្លាយជាស្នូលនៃសន្តិភាព ស្ថិរភាព និងវិបុលភាពសម្រាប់តំបន់ ហើយនៅក្នុងន័យនេះ អាស៊ានត្រូវបន្តពង្រឹងប្រសិទ្ធភាពស្ថាប័នសំខាន់ៗរបស់ខ្លួន ដើម្បីដោះស្រាយភាពស្មុគស្មាញនៃការប្រកួតប្រជែងភូមិសាស្ត្រយុទ្ធសាស្ត្រ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានលើកទឹកចិត្តដល់ប្រទេសសមាជិកអាស៊ានបន្តជំរុញពាណិជ្ជកម្មរវាងប្រទេសសមាជិកអាស៊ាន ស្វែងរកប្រភពនៃកំណើនថ្មី និងធានាឱ្យបាននូវការអនុវត្តពេញលេញ និងមានប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា ជាពិសេស កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)។

ដោយបានកត់សម្គាល់ដោយពេញចិត្តចំពោះមុខមាត់ និងសមត្ថភាពរបស់អាស៊ាន ដែលធ្វើឱ្យប្រទេសខាងក្រៅតំបន់ជាច្រើនចង់មកធ្វើការជាមួយ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់ពីសារៈសំខាន់ ដែលអាស៊ានត្រូវបន្តបង្កើនសមត្ថភាពស្ថាប័នដោយឥតឈប់ឈរ ក្នុងការគ្រប់គ្រងភាពជាដៃគូទាំងនេះ ដើម្បីបានជាប្រយោជន៍ដល់ប្រជាជនអាស៊ានទាំងមូល តាមរយៈការលើកកម្ពស់កិច្ចសហការប្រកបដោយផ្លែផ្កាលើគ្រប់វិស័យជាមួយដៃគូខាងក្រៅ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានរំលឹកឡើងពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការរួមចំណែកធ្វើឱ្យតំបន់អាស៊ីអាគ្នេយ៍ជាតំបន់គ្មានអាវុធនុយក្លេអ៊ែរ ហើយបានកោតសរសើរចិនដែលបានត្រៀមខ្លួនរួចជាស្រេចចូលជាភាគីនៃសន្ធិសញ្ញាស្តីពីតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ (SEANWFZ) ដោយគ្មានឧបសម្រុង។ ការណ៍នេះ បើសម្រេចបាន នឹងជំរុញលើកទឹកចិត្តដល់រដ្ឋដែលមានអាវុធនុយក្លេអ៊ែរផ្សេងទៀត ចូលជាភាគីនៃសន្ធិសញ្ញានេះផងដែរ។

## ២. កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន លើកទី២៧

កិច្ចប្រជុំបានស្វាគមន៍ចំពោះការខិតខំប្រឹងប្រែងរបស់ប្រទេសសមាជិកអាស៊ាន ក៏ដូចជាស្ថាប័នពាក់ព័ន្ធ និងលេខាធិការដ្ឋានអាស៊ាន ដែលបានអនុវត្តបន្ទាត់សកម្មភាពនៃផែនការលម្អិតស្តីពីសហគមន៍នយោបាយ-សន្តិសុខអាស៊ានឆ្នាំ២០២៥ ដោយសម្រេចដល់ទៅ ៩៩% ដែលសកម្មភាពទាំងនោះក៏បានគ្រប់ដណ្តប់លើវិស័យពាក់ព័ន្ធនឹងទស្សនវិស័យអាស៊ានស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិក (AOIP) សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណេត បញ្ញាសិប្បនិម្មិត បដិវត្តន៍ឧស្សាហកម្មទី៤ សេដ្ឋកិច្ចបៃតង ការ

ឆ្លើយតបរបស់អាស៊ានចំពោះការរីករាលដាលនៃជំងឺកូវីដ-១៩ របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ (WPS) និងរបៀបវារៈយុវជន សន្តិភាព និងសន្តិសុខ (YPS) ផងដែរ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានវាយតម្លៃថា សន្តិភាព និងស្ថិរភាព គឺជាឆ្អឹងខ្នងដ៏សំខាន់នៃរាល់ការអភិវឌ្ឍទាំងអស់ ហើយយន្តការដែលដឹកនាំដោយអាស៊ានត្រូវបន្តលើកកម្ពស់សន្តិភាព និងស្ថិរភាព នៅក្នុងតំបន់ ជាពិសេស បញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងបញ្ហាដែលនឹងកើតឡើងនាពេលអនាគត។ ស្របពេលជាមួយគ្នានេះដែរ ប្រទេសសមាជិកអាស៊ានត្រូវតែយកចិត្តទុកដាក់រួមគ្នាដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់រូបភាព ដែលត្រូវបានមើលឃើញថា មាននិន្នាការកើនឡើងក្រោមជំនួយផ្នែកបច្ចេកវិទ្យា។ ឆ្លៀតក្នុងឱកាសនេះផងដែរ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណដល់ប្រទេសសមាជិកអាស៊ាន ដែលបានរួមចំណែកដល់ដំណើរការមជ្ឈមណ្ឌលសកម្មភាពមីនតំបន់អាស៊ាន (ARMAC) និងអំពាវប្រទេសសមាជិកអាស៊ានទាំងអស់ផ្តល់ការគាំទ្រចាំបាច់នានាដល់មជ្ឈមណ្ឌល ARMAC។

## ៣. <u>កិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន (ACC) លើកទី៣៤</u>

រដ្ឋមន្ត្រីការបរទេសអាស៊ានក៏បានលើកឡើងសាជាថ្មីថា ការពិគ្រោះយោបល់ និងគោលការណ៍កុងសង់ស៊ុស នៅតែជាយន្តការដែលមិនអាចបំពានបាន នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់អាស៊ាន ដែលស្របតាមធម្មនុញ្ញអាស៊ាន។ កិច្ចប្រជុំបានឯកភាពដាក់ជូននូវវិធាននីតិវិធីនៃការគាំទ្រដំណើរការធ្វើសេចក្តីសម្រេចរបស់កិច្ចប្រជុំអាស៊ាន និងឯកសារចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០៤៥ សម្រាប់កិច្ចប្រជុំកំពូលអាស៊ានលើកទី៤៣ ដើម្បីកត់សម្គាល់ និងទន្ទឹងរង់ចាំការសម្រេចបានពេញលេញនូវឯកសារផែនការលម្អិតនិងផែនការជាយុទ្ធសាស្ត្រនៃចក្ខុវិស័យនេះ ដើម្បីអនុម័តនៅឆ្នាំ២០២៥។

កិច្ចប្រជុំបានកត់សម្គាល់នូវការឯកភាពលើក្របខ័ណ្ឌការងារសេដ្ឋកិច្ចពណ៌ខៀវអាស៊ាន ដោយក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលនឹងត្រូវដាក់ជូនកិច្ចប្រជុំអាស៊ានលើកទី៤៣ ដើម្បីអនុម័ត។ រដ្ឋមន្ត្រីការបរទេសអាស៊ានបានយល់ព្រមតាមសំណើប្រធានអាស៊ាន (ឥណ្ឌូនេស៊ី) ក្នុងការបង្កើតក្រុមការងារចំពោះកិច្ចស្តីពីសេដ្ឋកិច្ចពណ៌ខៀវ និងបានចាត់ឱ្យលេខាធិការដ្ឋានអាស៊ានសិក្សារៀបចំទម្រង់នៃការបង្កើតក្រុមការងារចំពោះកិច្ចនេះ។ រដ្ឋមន្ត្រីការបរទេសអាស៊ានបានស្វាគមន៍នូវវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីបដិវត្តន៍ឧស្សាហកម្មទី៤ និងបានឯកភាពលើសេចក្តីព្រាងសេចក្តីថ្លែងការណ៍របស់ប្រមុខដឹកនាំអាស៊ានស្តីពី **"អាស៊ានជាស្នូលនៃកំណើន"** ដើម្បីដាក់ជូនកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៣ អនុម័ត។

ពាក់ព័ន្ធនឹងផែនទីចង្អុលផ្លូវសម្រាប់សមាជិកពេញសិទ្ធិរបស់ទីម័រឡេស្តេក្នុងអាស៊ាន កិច្ចប្រជុំបានផ្លាស់ប្តូរយោបល់ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនទីចង្អុលផ្លូវនេះ និងបានប្តេជ្ញាចិត្តសហការគ្នាជាធ្លុងមួយ រវាងប្រទេសសមាជិកអាស៊ាន ដើម្បីជួយនៅក្នុងការធ្វើដំណើររបស់ទីម័រឡេស្តេ ដោយផ្តល់នូវបទពិសោធន៍ សមត្ថភាព និងជាពិសេសគំនិតផ្តួចផ្តើមកសាងសមត្ថភាពនានា។

## ៤. ពិធីចុះហត្ថលេខាលើសន្ធិសញ្ញាស្តីពី មិត្តភាពនិងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC) ដោយ សាធារណរដ្ឋសែប៊ី សាធារណរដ្ឋប៉ាណាម៉ា និងរដ្ឋកូវ៉ែត

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងរដ្ឋមន្ត្រីការបរទេសអាស៊ានផ្សេងទៀត បានអញ្ជើញចូលរួមជាសាក្សីនៅក្នុងពិធីចុះហត្ថលេខាលើលិខិតូបករណ៍ចូលជាភាគី នៃសន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការ នៅអាស៊ីអាគ្នេយ៍ របស់សាធារណរដ្ឋសែប៊ី សាធារណរដ្ឋប៉ាណាម៉ា និងរដ្ឋកូវ៉ែត។ ការចុះហត្ថលេខាលើលិខិតូបករណ៍របស់ប្រទេសទាំង៣នេះ បានធ្វើឱ្យភាគីនៃ TAC កើនដល់ចំនួន ៥៤។

ទន្ទឹមនឹងនេះ រដ្ឋមន្ត្រីការបរទេសអាស៊ានក៏រំពឹងរង់ចាំការចុះហត្ថលេខាចូលជាភាគីនៃ TAC ដោយអ៊េស្បាញ មិចស៊ិកកូ អាល់ហ្សេរី និងលុចហ្សំបួរ ក្នុងពេលឆាប់ៗខាងមុខ។

## ៥. ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងអាស៊ានជាមួយវេទិកាកោះប៉ាស៊ីហ្វិក (PIF) និងសមាគមមហាសមុទ្រឥណ្ឌា (IORA)

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងរដ្ឋមន្ត្រីការបរទេសអាស៊ានដទៃទៀត ក៏បានអញ្ជើញធ្វើជាសាក្សី ក្នុងការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ចំនួន២ ដោយឡែកពីគ្នា៖ ១. រវាងអគ្គលេខាធិការអាស៊ាន និងអគ្គលេខាធិការនៃសមាគមមហាសមុទ្រឥណ្ឌា និង ២. រវាងអគ្គលេខាធិការអាស៊ាន និងអគ្គលេខាធិការរងនៃវេទិកាកោះប៉ាស៊ីហ្វិក។

## ៦. ជំនួបទ្វេភាគី

ក្នុងឱកាសនៃការចូលរួមកិច្ចប្រជុំខាងលើ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានអនុញ្ញាតជូន **ឯកឧត្តមបណ្ឌិត កៅ គឹមហួន** អគ្គលេខាធិការអាស៊ាន ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ ព្រមទាំងមានជំនួបទ្វេភាគីជាមួយ ១. **ឯកឧត្តម វីវៀន បាឡាគ្រីស្សណាន់** រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសិង្ហបុរី, ២. **ឯកឧត្តម អ៊ីវីកា ដាស៊ីក** ឧបនាយករដ្ឋមន្ត្រីទី១ និងជារដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសែប៊ី និង ៣. **លោកជំទាវ អាណា សេស៊ីលៀ ជើវ៉ាស៊ី** រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋប៉េរូ ដើម្បីពង្រឹងទំនាក់ទំនងទ្វេភាគីបន្ថែមទៀត និងបានផ្លាស់ប្តូរទស្សនៈអំពីបញ្ហានានា ដែលជាផលប្រយោជន៍រួម។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានចុះហត្ថលេខាជាមួយសមភាគីសែប៊ីលើអនុស្សរណៈយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានការទូតនៃក្រសួងការបរទេសទាំងពីរ និងជាមួយសមភាគីប៉េរូលើអនុស្សរណៈយោគយល់គ្នាស្តីពី ការបង្កើតកិច្ចពិគ្រោះយោបល់ទ្វេភាគីរវាងក្រសួងការបរទេសទាំងពីរ៕

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖
ឈ្មោះ៖ អាន សុខខឿន
ទូរស័ព្ទ៖ 069 567 169 (Telegram និងWhatsApp)
អ៊ីមែល៖ mfaic@mfaic.gov.kh